**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៩ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការទទួលដីប្រមាណ ២០ហិកតា នៅភូមិស្រះកែវ ស្រុកសង្កែ ខេត្តបាត់ដំបង សំរាប់ធ្វើជាកន្លែងពិសោធន៍កសិកម្ម

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល
- ផ្អែកតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១.-** ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម **ចាន់ ណារ៉េត** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងជាអនុប្រធានគណៈកម្មការ ដូចមានចែងក្នុងសេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ឱ្យទទួលដីប្រមាណ ២០ហិកតា នៅភូមិស្រះកែវ ស្រុកសង្កែ ខេត្តបាត់ដំបង ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រគល់ជូនសាកលវិទ្យាល័យបាត់ដំបង សំរាប់ធ្វើជាកន្លែងពិសោធន៍ ។

**ប្រការ ២.-** ឯកឧត្តម **ចាន់ ណារ៉េត** មានភារកិច្ចដូចខាងក្រោម :

- ចាត់ចែង ការថែរក្សា និងគ្រប់គ្រងដីឱ្យបានល្អប្រសើរ
- ចាត់ចែងការកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅលើទីតាំងដីនោះ សំរាប់បំរើឱ្យការងារពិសោធន៍របស់និស្សិតសាកលវិទ្យាល័យបាត់ដំបង ដោយធ្វើការអំពាវនាវរកជំនួយឧបត្ថម្ភពីសប្បុរសជននានា

/.

- រាយការណ៍ និងបំពេញការងារមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** ។

**ប្រការ ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង និងឯកឧត្តម **ចាន់ ឈាវីត** ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ជ. នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**ស ខេង**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ដូចចែងក្នុងប្រការ ៣
- ឯកសារ កាលប្បវត្តិ